# សិក្ខាសាលាថ្នាក់ជាតិផ្សព្វផ្សាយ និងតម្រង់ទិស ស្តីពី

- និយាមបែបបទសម្រាប់ការអនុវត្ត ការកែលម្អគុណភាពបន្តនៃសេវាថែទាំជំងឺអេដស៍នៅកម្ពុជា
- លទ្ធផលការអនុវត្តការកែលម្អគុណភាពជាបន្តដោយវិធីសាស្ត្រផែនការ សកម្មភាព ត្រួតពិនិត្យ កែតម្រូវ ផែនការសកម្មភាពនៃសេវាថែទាំអ្នកជំងឺអេដស៍នៅកម្ពុជា
- លទ្ធផលការរកមូលហេតុនៃការស្លាប់ក្នុងចំណោមអ្នកជំងឺអេដស៍នៅកម្ពុជា
- លទ្ធផលស្តីពីចំណេះដឹង ម=ម ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍

**National Dissemination and Orientation Workshop on**

- Standard Operating Procedure (SOP) for the CQI for CoC for PLHIV in Cambodia
- Finding from documentation of implementation of CQI by PDCA at HIV care services in Cambodia
- Finding from documentation of mortality and its causes among PLHIV in Cambodia
- Finding from documentation of knowledge of PLHIV on U=U



*ថ្ងៃ អង្គារ ១២ រោច ដល់ ថ្ងៃ ពុធ ១៣ រោច ខែអាសាឍ ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី ២៦-២៧ ខែ កក្កដា ឆ្នាំ២០២២ នៅសាលប្រជុំមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកំពត មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានរៀបចំ* ***សិក្ខាសាលាថ្នាក់ជាតិផ្សព្វផ្សាយ និងតម្រង់ទិស ស្តីពី:***


- *និយាមបែបបទសម្រាប់ការអនុវត្ត ការកែលម្អគុណភាពបន្តនៃសេវាថែទាំជំងឺអេដស៍នៅកម្ពុជា*
- *លទ្ធផលការអនុវត្តការកែលម្អគុណភាពជាបន្តដោយវិធីសាស្ត្រផែនការ សកម្មភាព ត្រួតពិនិត្យ កែតម្រូវ ផែនការសកម្មភាពនៃសេវាថែទាំអ្នកជំងឺអេដស៍នៅកម្ពុជា*
- *លទ្ធផលការរកមូលហេតុនៃការស្លាប់ក្នុងចំណោមអ្នកជំងឺអេដស៍នៅកម្ពុជា*
- *លទ្ធផលស្តីពីចំណេះដឹង ម=ម ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍*

ដោយមានការចូលរួម សិក្ខាកាមមកពីខេត្តចំនួន ១០ **ខេត្តកំពត**មកពីមន្ទីរសុខាភិបាល (Local Coordinator and Opening & Closing) **ខេត្តព្រៃវែង**មកពីមន្ទីរសុខាភិបាលព្រៃវែង (មន្ទីរពេទ្យបង្អែកខេត្តព្រៃវែង អ្នកលឿង និងពារាំង) **ខេត្ត កោះកុង** មកពីមន្ទីរសុខាភិបាល មន្ទីរពេទ្យបង្អែកខេត្តកោះកុង និងស្រែអំបិល **ខេត្ត កំពង់ចាម** មកពីមន្ទីរសុខាភិបាល មន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម ជើងព្រៃ ចំការលើ និងបាធាយ **ខេត្តត្បូងឃ្មុំ** មកពីមន្ទីរសុខាភិបាល មន្ទីរពេទ្យបង្អែកខេត្តត្បូងឃ្មុំ និងមេមត់ **ខេត្តកំពង់ឆ្នាំង** មកពីមន្ទីរសុខាភិបាល មន្ទីរពេទ្យបង្អែកខេត្តកំពង់ឆ្នាំង និងកំពង់ត្រឡាច **ខេត្តកណ្តាល** មកពីមន្ទីរសុខាភិបាល មន្ទីរពេទ្យបង្អែកខេត្តជ័យជំនះ កោះធំ និងកៀនស្វាយ **ខេត្តប៉ៃលិន** មកពីមន្ទីរសុខាភិបាល មន្ទីរពេទ្យបង្អែកខេត្តប៉ៃលិន **ខេត្តពោធិ៍សាត់** មកពីមន្ទីរសុខាភិបាល មន្ទីរពេទ្យបង្អែកខេត្តពោធិ៍សាត់ បាកាន និងក្រវ៉ាញ និង**ខេត្តសៀមរាប** មកពីមន្ទីរសុខាភិបាល មន្ទីរពេទ្យបង្អែកខេត្តសៀមរាប សូត្រនិគម និងក្រឡាញ់ ដោយខេត្តនិមួយៗ មានប្រធានកម្មវិធីអេដស៍ខេត្ត PASP និង ART Clinician មកពី ART Service ជាអ្នកចូលរួម និង អង្គការ US-CDC, AHF, FHI360-EpiC, CRS, and Chhouk Sar Association។ អ្នកចូលរួមសរុបទាំងអស់ចំនួន ៦៤ នាក់។

- ពិធីបើក នាព្រឹកថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០២២ សិក្ខាសាលានេះបានចាប់ផ្តើមនៅម៉ោង 8:00 ព្រឹក
  - មតិស្វាគមន៍ដោយ**លោកវេជ្ជ. តាន់ ឆេង** អនុប្រធានមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកំពត។
  - មតិចំណាប់អារម្មណ៍ដោយលោក**វេជ្ជ. ចាន់ សូដារា** តំណាង US- DC, Cambodia.
  - មតិចំណាប់អារម្មណ៍ប្រកាសបើក សិក្ខាសាលា ដោយ**លោក វេជ្ជ. កាអឿន ចិត្រា** អនុប្រធានការិយាល័យបច្ចេកទេស និងជាប្រធានផ្នែកគ្រប់គ្រងទិន្នន័យ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

